អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ ២០១៧

# សេចក្តីប្រកាសព័ត៌មាន
# របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត

## សេចក្តីជូនដំណឹងអំពីការបកស្រាយទៅលើ "ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលពាក់ព័ន្ធនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបមួយ

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ** បានចេញសេចក្តីសម្រេចទៅលើថាតើ ការវាយប្រហារប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបមួយ អាចត្រូវបានចាត់ទុកថាជាការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល ដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលនៅជាធរមានពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែរឬទេ។

នៅក្នុងសេចក្តីសម្រេច កាលពីថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានជូនដំណឹងទៅភាគីក្នុងសំណុំរឿង ០០៣ និង ០០៤ អំពីការយល់ឃើញរបស់គាត់ថា នៅក្នុងបរិបទនៃច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬរបបមួយ ប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនផ្ទាល់ អាចចាត់ទុកថាជាការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល ដែលមានចែងក្នុងមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក លើកលែងតែកងកម្លាំងប្រដាប់អាវុធនោះបានចងសម្ព័ន្ធភាព ឬផ្តល់ការគាំទ្រផ្នែកយោធាដែលពាក់ព័ន្ធទៅភាគីម្ខាងទៀតក្នុងជម្លោះប្រដាប់អាវុធមួយ។

សេចក្តីសម្រេចខាងលើនេះត្រូវបានចេញ បន្ទាប់ពីមានសំណើសុំសេចក្តីសន្និដ្ឋានពីភាគី និងអ្នកដែលមិនមែនជាភាគីនៃរឿងក្តី ក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលបានដាក់កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ (https://www.eccc.gov.kh/en/articles/international-co-investigating-judge-calls-submission-amicus-

curiae-briefs)។ សេចក្តីសម្រេចនេះគឺជាលើកដំបូងបំផុតដែលតុលាការបានដោះស្រាយបញ្ហាអង្គច្បាប់នេះយ៉ាងទូលំទូលាយ។

សេចក្តីសម្រេចនេះអាចរកមើលបាននៅលើគេហទំព័រ៖
https://eccc.gov.kh/en/document/court/notification-interpretation-%E2%80%98attack-against-civilian-population%E2%80%99-context-crimes-again

*ចំពោះព័ត៌មានបន្ថែមទៀត សូមទាក់ទង៖*


**លោកស្រី ហាយ៉ាត់ អាប៊ូ-សាឡេស**
មន្ត្រីព័ត៌មានសាធារណៈ
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ៩៣៦
ទូរស័ព្ទលើតុ: +៨៥៥ (0) ២៣ ៨៦០ ១៩១
សារអេឡិចត្រូនិក៖ abusaleh@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ: +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh